**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០) |
| **ដាក់ទៅ** | ៖ | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | ៖ | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Mar-2019, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖** **សម្ងាត់/Confidential**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**

**ហត្ថលេខា៖**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២

---

**អ្នកដាក់ឯកសារ៖**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន៖**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jim BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

**សហមេធាវី អោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) បានចេញដីកាដំណោះស្រាយមួយ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) ដោយបានចោទប្រកាន់ អោ អាន ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើបំពារបំពានទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងដោយបានបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ (“ស.ច.ស.ជ”) បានចេញដីកាដំណោះស្រាយមួយ (“ដីកាលើកលែងចោទប្រកាន់”) ដោយបានទម្លាក់រាល់បទចោទទាំងអស់ប្រឆាំងនឹង អោ អាន ដោយផ្អែកលើទឡ្ហីករណ៍ដែលថា គាត់មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[2]។ សហព្រះរាជអាជ្ញាជាតិ (“ស.ព.ជ”) បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (“បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ”) ដោយអះអាងថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ អោ អាន ពីព្រោះគាត់មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[3]។ ពេលនេះសហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) សូមធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ។

## II. ប្រវត្តិនីតិវិធី និង ច្បាប់ជាធរមាន

2. ស.ព.អ សូមដាក់បញ្ចូលជាឯកសារយោងនូវប្រវត្តិនីតិវិធីដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ I ភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់[4]។

3. បន្ថែមលើនេះទៀត នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) បានសម្រេចពន្យារពេល និងបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតបរបស់ភាគី ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ ដោយបានណែនាំពួកគាត់ឲ្យដាក់ចម្លើយតបដែលមានកម្រាស់ ៥០ទំព័រ នៅក្នុងរយៈពេល ៣០ថ្ងៃ ដោយគិតពីថ្ងៃជូនដំណឹងអំពីការបកប្រែបណ្តឹង

[1] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) KH 01588970-78។

[2] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាលើកលែងការចោទប្រកាន់”) កថាខណ្ឌ ៥៥៤-៥៥៥។

[3] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ (“បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ”)។

[4] ឯកសារ **D359/3/1.2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ អោ អាន ឧបសម្ព័ន្ធ Iៈ ប្រវត្តិនីតិវិធី ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

ឧទ្ធរណ៍ដែលពួកគាត់ត្រូវឆ្លើយតបនោះ[5]។ ការបកប្រែជាភាសាអង់គ្លេសលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩[6] ដែលបានធ្វើឲ្យចម្លើយតបនេះត្រូវដល់ពេលកំណត់នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

4. ច្បាប់ជាធរមាន បានបង្ហាញនៅក្នុងផ្នែកពាក់ព័ន្ធខាងក្រោមនេះ។

## III. សេចក្តីសន្និដ្ឋាន

5. សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ (i) ខកខានមិនបានបញ្ជាក់ពីកំហុសផ្នែកអង្គហេតុជាក់ស្តែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (ii) មិនយកចិត្តទុកដាក់ទៅលើចេតនាច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ("អ.ស.ប") នៅក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀង អ.វ.ត.ក។ (iii) ខកខានមិនបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានអំណាចជាឯកតោភាគីក្នុងការកម្រិតយុត្តាធិការបុគ្គលដោយគ្មានការធ្វើវិសោធនកម្មកិច្ចព្រមព្រៀង អ.វ.ត.ក ឬ ច្បាប់ អ.វ.ត.ក ជាផ្លូវការ។ និង (iv) អះអាងដោយមិនមានភាពជឿជាក់ថា សំណុំរឿង០០១ និង ០០២ បានផ្តល់យុត្តិធម៌គ្រប់គ្រាន់ដល់ប្រជាជនកម្ពុជា។

### ក. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មិនបានបង្ហាញពីកំហុសផ្នែកអង្គហេតុណាមួយឡើយ

6. ក្នុងនាមជាម្ចាស់បណ្តឹងឧទ្ធរណ៍ដែលចោទប្រកាន់ពីកំហុសផ្នែកអង្គហេតុ ស.ព.ជ មានបន្ទុកក្នុងការបង្ហាញឲ្យឃើញថា ពុំមានអ្នកវិនិច្ឆ័យឥតលម្អៀងទៅលើអង្គហេតុណាម្នាក់បានធ្វើសំអាងហេតុដែលត្រូវបានជំទាស់នេះទេ[7]។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មិនបានបង្ហាញថា ការរកឃើញផ្នែកអង្គហេតុណាមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនសមហេតុសមផលនោះឡើយ។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍នេះគ្រាន់តែបង្ហាញពីទស្សនៈខុសគ្នាអំពី

---

[5] ឯកសារ **D360/5/3** សាលដីកាលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ សម្រាប់ចម្លើយតបនិងការឆ្លើយតបទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩។

[6] *សូមអាន* អ៊ីមែលពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ម៉ោង៖ ១១:៣២ ព្រឹក។

[7] *សូមអាន ឧទា.* សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ១១៣។ *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងគូកន* សំណុំរឿងលេខ IT-04-84-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១២។ *រដ្ឋអាជ្ញា ទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៤។

អង្គហេតុទាំងនោះ ដោយពុំមានការលើកឡើងដោយផ្ទាល់ (ឬសូម្បីតែការយោងទៅលើ) ពីការរកឃើញផ្នែកអង្គហេតុណាមួយរបស់ ស.ចៅ.ស.អ ឡើយ[8]។ វិធីសាស្ត្រនេះ ខកខានមិនបានបំពេញបន្ទុកក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ នោះទេ។ ហេតុដូច្នេះ ផ្នែកអង្គហេតុនៃបណ្តឹងឧទ្ធរណ៍ របស់ ស.ព.ជ គួរត្រូវបានបដិសេធចោល។

7. បន្ថែមលើនេះ ការអះអាងផ្នែកអង្គហេតុនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មិនមានភ័ស្តុតាងគាំទ្រទេ នៅពេលដែលការស៊ើបអង្កេតក្នុងសំណុំរឿង០០៤/២ ត្រូវបានពិចារណាទាំងមូល។ ស.ព.អ បានលើកឡើងរួចហើយអំពីការអះអាងមិនត្រឹមត្រូវភាគច្រើនក្នុងចំណោមការអះអាងមិនត្រឹមត្រូវលើអង្គហេតុទាំងនេះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់របស់ ស.ចៅ.ស.ជ[9]។

**ខ. ទាំងរាជរដ្ឋាភិបាលកម្ពុជា និងទាំង អ.ស.ប មានបំណងថា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ជាប្រភេទបើកចំហរ ដែលសមាជិកភាពរបស់ពួកគាត់ នឹងត្រូវបានកំណត់ដោយតុលាការ**

8. ស.ព.ជ បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ("កិច្ចព្រមព្រៀង អ.វ.ត.ក") និង

---

[8] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៦៨-៨៣។

[9] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់")។ ជាឧទាហរណ៍៖ (i) សេចក្តីអះអាងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ដែលថា ការអត់ឃ្លាន និង ជម្ងឺ គឺជាមូលហេតុដែលគ្របសង្កត់លើការស្លាប់ក្នុងកំឡុងពេលដែល អោ អាន នៅភូមិភាគកណ្តាល (កថាខណ្ឌ ៧៣) ត្រូវបានលើកឡើងនៅត្រង់កថាខណ្ឌ ៨៣-៨៤ នៃបណ្តឹងឧទ្ធរណ៍របស់ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ (ii) ការស្នើឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ដែលថា ការបោសសម្អាតកម្មាភិបាលដែលកំពង់រស់នៅភូមិភាគកណ្តាល ត្រូវបានបញ្ចប់ភាគច្រើននៅមុនការទៅដល់នៃកម្មាភិបាលភូមិភាគនិរតី (កថាខណ្ឌ ៧៤) ត្រូវបានដោះស្រាយនៅក្នុងកថាខណ្ឌ ៨៥-៨៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ (iii) ការអះអាងក្នុងបណ្តឹងឧទ្ធរណ៍ របស់ ស.ព.ជ ដែលថា អោ អាន ជាលេខាតំបន់៤១ អស់រយៈពេលតែ "ប្រហែលជាមួយឆ្នាំ" (កថាខណ្ឌ ៧៥) ត្រូវបានពិភាក្សានៅត្រង់កថាខណ្ឌ ៧៣-៧៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ and (iv) និងការស្នើឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ដែលថា អោ អាន ត្រូវស្ថិតនៅក្រោមកាលៈទេសៈបង្ខិតបង្ខំដែលមិនអាចគេចរួចបាន ដែលថាមិនបានទុកឱ្យគាត់នូវជម្រើសណាមួយ ក្រៅតែពីប្រព្រឹត្តឧក្រិដ្ឋកម្ម (កថាខណ្ឌ ៨៣) ត្រូវបានលើកឡើងនៅត្រង់កថាខណ្ឌ ៣២-៤១ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។

ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ អ.វ.ត.ក")[10]។ ក្របខណ្ឌគតិយុត្តិទាំងពីរនេះចែងថា យុត្តាធិការត្រូវបានកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់[11]។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ អះអាងមិនត្រឹមត្រូវថា "គោលគំនិត" របស់រាជរដ្ឋាភិបាលកម្ពុជា "នៅក្នុងកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" គឺថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើតែប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ប៉ុណ្ណោះ ហើយហេតុដូច្នេះ ការបន្តសំណុំរឿងប្រឆាំងនឹង អោ អាន នឹងពង្រីកវិសាលភាពយុត្តាធិការបុគ្គលរបស់តុលាការនេះមិនត្រឹមត្រូវ[12]។

9. ការបកស្រាយបែបដូច្នេះ មិនត្រូវបានគាំទ្រដោយសេចក្តីថ្លែងការរបស់មន្ត្រីផ្លូវការនៃរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលមានការចរចាលើកិច្ចព្រមព្រៀង អ.វ.ត.ក និងការអនុម័តច្បាប់ អ.វ.ត.ក ឡើយ។ ជាឧទាហរណ៍ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាជាសាធារណៈថា រាជរដ្ឋាភិបាលកម្ពុជា នឹងមិនជ្រៀតជ្រែកតាមរូបភាពណាមួយក្នុងកិច្ចការ អ.វ.ត.ក នោះទេ រួមទាំង នៅក្នុងការកំណត់ថា តើមានមនុស្សចំនួនប៉ុន្មាននាក់គួរត្រូវបានយកមកកាត់ទោសនោះ។ នៅខែមីនា ឆ្នាំ១៩៩៩ គាត់បានប្រាប់ទៅលោកអគ្គលេខាធិការ អ.ស.ប ថាៈ

> រាជរដ្ឋាភិបាលកម្ពុជាមិនមានអំណាចអ្វីដើម្បីដាក់ក្រិតអ្វីទៅលើតុលាការមានសមត្ថកិច្ច ធ្វើតាមនោះទេ។ [...] បញ្ហាថាតើត្រូវកាត់ទោស តាម៉ុក តែម្នាក់ឯង ឬមេដឹកនាំខ្មែរ ក្រហមដទៃទៀត អាស្រ័យទាំងស្រុងលើតុលាការមានសមត្ថកិច្ច។ រាជរដ្ឋាភិបាលកម្ពុជា នឹងមិនប្រើប្រាស់ឥទ្ធិពលណាមួយ ឬជ្រៀត

---

[10] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៨៥។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក")។

[11] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់ អ.វ.ត.ក មាត្រា ១។

[12] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៩១, ៩៦។

ជ្រែកក្នុងទម្រង់ណាក៏ដោយ ទៅក្នុងកិច្ចដំណើរការនីតិវិធីធម្មតារបស់តុលាការ ដែលនឹងទទួលបានឯករាជ្យភាពពេញលេញ ពីអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ[13]។

10. មួយខែក្រោយមក នៅក្នុងកិច្ចប្រជុំមួយ នៅខែមេសា ឆ្នាំ១៩៩៩ ជាមួយនឹងព្រឹទ្ធសភា ស.រ.អា លោក John Kerry ដែលជាអ្នកចូលរួមនៅក្នុងការចរចានោះ លោក ហ៊ុន សែន បានបញ្ជាក់ទៅកាន់លោកព្រឹទ្ធសភា Kerry ថា៖

> ការបញ្ជូនរឿងទៅជំនុំជម្រះ និងការចោទប្រកាន់ពួកមេដឹកនាំខ្មែរក្រហម គឺជាសម្ថកិច្ចតែមួយគត់របស់តុលាការ។ រាជរដ្ឋាភិបាលមិនមានសិទ្ធិក្នុងការផ្តល់បញ្ជាឲ្យទៅផ្នែកតុលាការថាត្រូវធ្វើនេះ ឬធ្វើនោះទេ[14]។

11. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ បានលើកឡើងយ៉ាងត្រឹមត្រូវថា បញ្ហានៃចំនួនមនុស្សដែលត្រូវនាំយកទៅកាត់ទោស "មានការជជែកវែកញែកគ្នាយ៉ាងតឹងតែង នាពេលប្រជុំរដ្ឋសភាដើម្បីពិភាក្សា និង អនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក" ក៏ប៉ុន្តែខកខានមិនបានផ្តល់នូវសេចក្តីពិស្តារអំពីការពិភាក្សានោះ អំពីអ្វីដែលរាជរដ្ឋាភិបាលចង់មានន័យចំពោះពាក្យថា "ទទួលខុសត្រូវ

---

[13] លិខិត ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ ពីលោកនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ផ្ញើរជូនលោកអគ្គលេខាធិការ ឯកសាររបស់ អ.ស.ប A/៥៣/៨៧៥, S/១៩៩៩/៣២៤ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ២-៣។ *សូមកត់សម្គាល់ថា* នៅក្នុងកថាខណ្ឌ ៤ លោក ហ៊ុន សែន បានស្នើសុំឲ្យផ្សព្វផ្សាយលិខិតនេះជាឯកសាររបស់មហាសន្និបាត។

[14] សេចក្តីថ្លែងការណ៍ បានធ្វើឡើងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៩ ដោយខុទ្ទកាល័យរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកសាររបស់ អ.ស.ប លេខA/៥៣/៩១៦ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៩។ បន្ថែមលើនេះ "បន្ទាប់ពីការទទួលបានការធានាទាំងនេះពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកព្រឹទ្ធសភា John Kerrry បានស្វាគមន៍នូវគោលជំហរជាវិជ្ជមានរបស់លោកនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា"។ *សូមអានផងដែរ* សារព័ត៌មានអន្តរជាតិ Kyodo, *ហ៊ុន សែន សោកស្តាយដោយបានថ្លែងថាមេដឹកនាំខ្មែរក្រហមមួយចំនួនត្រូវបានកាត់ទោស*, ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០០ [នៅក្នុងបទសម្ភាសមួយជាមួយបណ្តាញសារព័ត៌មានជប៉ុន. "លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានបញ្ជាក់ពីការសោកស្តាយកាលពីថ្ងៃសុក្រ ដោយបានថ្លែងថា មេដឹកនាំខ្មែរក្រហម 'បួន ទៅ ប្រាំ' នាក់នឹងត្រូវបានដាក់ឲ្យកាត់ទោស [...]។ គាត់បាននិយាយថា 'ខ្ញុំមិនត្រូវធ្វើអត្ថាធិប្បាយអ្វីលើរឿងនេះទេ ឬក៏និយាយអ្វីនៅក្នុងដែនកំណត់របស់តុលាការទេ'។ [...] លោក ហ៊ុន សែន បាននិយាយថា បុគ្គលណាមួយដែលបាននិយាយឲ្យច្បាស់លាស់ពីចំនួនមេដឹកនាំដែលត្រូវកាត់ទោស 'គឺខុសហើយ ហើយថារឿងនោះមានរួមទាំងអ្នកជំនាញច្បាប់របស់ អ.ស.ប ផងដែលបានពោលថាមានមនុស្ស ២០ ឬ ៣០ នាក់'។ លោកនាយករដ្ឋមន្ត្រីបាននិយាយថា ដោយការផ្តល់នូវចំនួនជាក់លាក់មួយពីមេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោស គឺ 'យើងបានបំពានលើតុលាការមួយដែលប្រើច្បាប់'"]។

ខ្ពស់បំផុត”[15]។ ប្រតិចារឹកនៃការពិភាក្សាដេញដោយ ខែតុលា ឆ្នាំ២០០៤ បានរំឮកពីការពិភាក្សានេះ ហើយ ស.ព.អ សន្និដ្ឋានថា ការបង្ហាញដែលបានធ្វើទៅកាន់សភាជាតិ ដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានដឹកនាំការចរចាសម្រាប់រាជរដ្ឋាភិបាលកម្ពុជា គឺជាភ័ស្តុតាងសំខាន់បំផុត អំពីគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជានៅពេលដែលកិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានធ្វើឡើង។ ប្រតិចារឹកនោះបង្ហាញថា អ្នកតាក់តែងច្បាប់រដ្ឋាភិបាលមួយចំនួនបានសុំឱ្យមានការបញ្ជាក់លើអ្វីទៅដែលអ្នកធ្វើសេចក្តីព្រាងមានន័យចំពោះពាក្យថា “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”៖

> ឯ.ឧ. លី ធុច៖ “ប្រជាជនយើង និងសង្គមស៊ីវិល ចង់សុំឱ្យឯកឧត្តម សុំបញ្ជាក់ឱ្យបានច្បាស់ថា តើនរណាខ្លះជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត? តើពួកគេរាប់បញ្ចូលទាំងប្រធានអង្គភាពរបស់អង្គការដែរឬទេ?”[16]។

> ឯ.ឧ. កែវ រ៉េមី៖ “តើនរណាខ្លះជាមេដឹកនាំជាន់ខ្ពស់? [...] តើប្រធានភូមិភាគត្រូវកាត់ទោសដែរឬទេ? ឬមួយថា ច្បាប់នេះគ្រាន់តែ[បាន]ធ្វើឡើងដើម្បីកាត់ទោសមេដឹកនាំ ៤ ឬ ៥ នាក់ប៉ុណ្ណោះ។ តើមាននរណាខ្លះទៀតដែលនឹងត្រូវកាត់ទោសដែរ? វាមិនមានយុត្តិធម៌ទេ បើយើងកាត់ទោសតែ ៣ ឬ ៤ នាក់នោះ”[17]។

> ឯ.ឧ. អេង ឆៃអ៊ាង៖ “ខ្ញុំក៏មិនច្បាស់ដែរចំពោះពាក្យ *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ តើជនទាំងនោះត្រូវទទួលខុសត្រូវប៉ុនណា? [...] ខ្ញុំចង់ឱ្យអ្នកតំណាងរដ្ឋាភិបាលធ្វើការបញ្ជាក់ថា ទំហំប៉ុនណាដែលពួកជនទាំងនោះត្រូវទទួលខុសត្រូវធំបំផុតនោះ។ [...] ខ្ញុំសូមរំឮកថា សូមកុំឱ្យប្រជាជនស្រពិចស្រពិល។ ប្រសិនបើយើងសង្កត់ធ្ងន់លើតែថ្នាក់ខ្ពស់បំផុត យើងចង់មានន័យថា ប៉ុល ពត ដែលបានស្លាប់បាត់ហើយនោះ”[18]។

---

[15] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៩១។

[16] ឯកសារ **D359/3/1.1.45** ប្រតិចារឹក បកប្រែដោយ DC-Cam នៃសម័យប្រជុំលើកទីមួយ នៃនីតិកាលទីបីរបស់រដ្ឋសភាជាតិកម្ពុជា ចុះថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤ (“ប្រតិចារឹកសភាជាតិ”) EN 01598760។

[17] ឯកសារ **D359/3/1.1.45** ប្រតិចារឹកសភាជាតិ EN 01598761។

[18] ឯកសារ **D359/3/1.1.45** ប្រតិចារឹកសភាជាតិ EN 01598762។

12. សុខ អាន បានឆ្លើយតបថា៖

> បើសិនជាយើងសួរសំណួរថា 'តើនរណាខ្លះនឹងត្រូវចោទប្រកាន់?" គឺទាំងអង្គការសហប្រជាជាតិ ទាំងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា មិនអាចផ្តល់ចម្លើយបានទេ។ ពីព្រោះរឿងនេះជាកិច្ចការរបស់តុលាការ៖ គឺអង្គជំនុំជម្រះវិសាមញ្ញ។ បើសិនជាយើងធ្វើបញ្ជីឈ្មោះមនុស្សសម្រាប់ការកាត់ទោសជំនួសតុលាការ នោះយើងបំពានលើអំណាចរបស់តុលាការ។ ដូច្នេះ យើងមិនអាចកំណត់អត្តសញ្ញាណថា ក, ខ, គ ឬ ឃ ជាអ្នកដែលត្រូវចោទប្រកាន់បានទេ។ ជាដំណោះស្រាយ យើងបានកំណត់អត្តសញ្ញាណក្រុមគោលដៅចំនួនពីរ៖ *មេដឹកនាំជាន់ខ្ពស់* និង *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ ចំពោះ *មេដឹកនាំជាន់ខ្ពស់* យើងសំដៅទៅលើមនុស្សមិនលើសពី ១០នាក់ទេ ក៏ប៉ុន្តែយើងមិននិយាយឲ្យច្បាស់ទេថា អ្នកទាំងនោះជាសមាជិកគណៈអចិន្ត្រៃយ៍។ រឿងនេះគឺជាកិច្ចការរបស់សហព្រះរាជអាជ្ញា ដែលត្រូវសម្រេចថានរណាខ្លះជាមេដឹកនាំជាន់ខ្ពស់។ [...] យ៉ាងណាក៏ដោយ វានៅតែមានក្រុមគោលដៅទីពីរទៀត។ ពួកគាត់មិនមែនជាមេដឹកនាំទេ ក៏ប៉ុន្តែពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។ ព្រោះហេតុនោះហើយបានជាយើងប្រើពាក្យថា *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ <u>វាមិនមានចំនួនមនុស្សជាក់លាក់នៅក្នុងក្រុមទីពីរនេះដែលត្រូវបានចោទប្រកាន់នោះទេ</u>[19]។

13. អ.ស.ប មានការយល់ឃើញដូចគ្នា។ នៅដើមដំណើរការក្នុងឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញដែលត្រូវបានចាត់តាំងដោយលោកអគ្គលេខាធិការ ដើម្បីស្វែងរកជម្រើសដែលនាំមកនូវយុត្តិធម៌ប្រសើរបំផុត បានថ្លែងថា៖

> ក្រុមនោះផ្តល់អនុសាសន៍ថា ការផ្តោតរបស់តុលាការទៅលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សក្នុងកំឡុងពេលកាន់កាប់របស់កម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះ រាប់បញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ដែលមានការ

---

[19] ឯកសារ **D359/3/1.1.45** ប្រតិចារឹកសភាជាតិ EN 01598763-64 (គូសបញ្ជាក់បន្ថែម)។ សម្រាប់ខ្លឹមសារពេញលេញទំព័រដែលបានកំណត់ថា សុខ អាន ជាវាគ្មិននៃសម្រង់នេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងការដាក់ឯកសារនេះ ជាឯកសារសំអាងផ្លូវច្បាប់ទី២០ អមទៅដោយទំព័រចំណងជើង និងសម្រង់ចំនួនពីរទំព័រ (ទំព័រទី១, ២៩-៣១)។ ទំព័រដែលបានកំណត់ថា សុខ អាន ជាវាគ្មិននៃសម្រង់នេះ មិនបានដាក់បញ្ចូលនៅក្នុងសម្រង់ប្រតិចារឹក ឯកសារ **D359/3/1.1.45** នេះទេ។

ទទួលខុសត្រូវចំពោះការរំលោភបំពាន ក៏ដូចជាជនទាំងឡាយនៅថ្នាក់ក្រោមដែលត្រូវបានជាប់ទាក់ទងផ្ទាល់នៅក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត។ យើងមិនចង់ផ្តល់នូវការកម្រិតតួលេខលើចំនួនមនុស្សបែបនោះ ដែលអាចត្រូវបានផ្តោតគោលដៅសម្រាប់ការស៊ើបអង្កេតនោះទេ។ យ៉ាងណាក៏ដោយ វាគឺជាការគិតរបស់ក្រុមនោះតាមរយៈការពិគ្រោះយោបល់ និងការស្រាវជ្រាវរបស់ខ្លួនថា ចំនួនមនុស្សដែលត្រូវកាត់ទោស អាចស្ថិតនៅចន្លោះពី ២០ ទៅ ៣០ នាក់[20]។

14. អនុសាសន៍ទាំងនេះ បានបង្កើតជាមូលដ្ឋានសម្រាប់គោលជំហរចរចារបស់ អ.ស.ប នៅពេលនោះ។ លោក David Scheffer បានរំឭកឡើងវិញពីអត្ថបទមួយដែលបានបោះពុម្ពផ្សាយនៅ ឆ្នាំ២០១១ ថា អ្នកចរចារបស់ អ.ស.ប លោក Ralph Zacklin បានទៅធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ នៅចុងខែសីហា ឆ្នាំ១៩៩៩ ហើយបានចាកចេញទៅវិញជាមួយនឹងការចាប់អារម្មណ៍ថា អាជ្ញាធរកម្ពុជាគ្រាន់តែចង់កាត់ទោស តាម៉ុក និង ឌុច តែប៉ុណ្ណោះ ប៉ុន្តែ គោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្តូរ ខណៈពេលដែលការចរចាបានដំណើរការទៅមុខ ក្នុងរយៈពេលចុងក្រោយនៃឆ្នាំ១៩៩៩ និង ឆ្នាំ២០០០[21]។ អត្ថបទនេះបានលំអិតពីការចូលរួមដោយផ្ទាល់របស់លោក Scheffer នៅក្នុងការចរចានោះ ជាពិសេសទាក់ទងទៅនឹងការពិចារណាពាក់ព័ន្ធនឹង ឌុច ហើយនិង ប្រភេទជនដែល "ទទួលខុសត្រូវខ្ពស់បំផុត"[22]។ គាត់បានសរសេរថាៈ "យើងគ្រាន់តែចាប់ អារម្មណ៍ទៅលើពួកមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ដែលបានបង្ហាញពីការទទួលខុសត្រូវដ៏សំខាន់ *ក៏ដូចជាពួកមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ឌុច* ដែលមានតួនាទីដ៏សំខាន់បែបនេះនៅក្នុងអំពើឃោរឃៅ"[23]។ ច្បាស់ណាស់ ការយល់ឃើញរបស់ អ.ស.ប គឺថា ប្រភេទនោះមិនត្រូវកម្រិតត្រឹមតែ ឌុច នោះទេ។

15. នៅខែមីនា ឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានស្នើឡើងនូវពាក្យថា "ជនទាំងឡាយដែលទទួលខុសត្រូវ" ដែលបានបើកទូលាយដល់ប្រភេទនេះហួសពីអ្វីដែល អ.ស.ប ធ្លាប់មានបំណង ហើយ

---

[20] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បានបង្កើតស្របតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៥២/១៣៥ ឯកសាររបស់ អ.ស.ប លេខ A/៥៣/៨៥០, S/១៩៩៩/២៣១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ("របាយការណ៍របស់ក្រុមអ្នកជំនាញរបស់ អ.ស.ប") កថាខណ្ឌ ១១០ (គូសបញ្ជាក់បន្ថែម)។

[21] Scheffer, D.J., "ប្រវត្តិនៃការចរចាស្តីពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក", Cambodia Tribunal Monitor, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ("អត្ថបទរបស់ Scheffer") ទំព័រទី ៣។

[22] អត្ថបទរបស់ Scheffer ជាក់ស្តែង ទំព័រទី ៣-៥។

[23] អត្ថបទរបស់ Scheffer ទំព័រទី ៥ (ការសង្កត់ន័យបន្ថែមត្រូវបានដកចេញ និងត្រូវបានបន្ថែម)។

លោក Kofi Annan អគ្គលេខាធិការរបស់ អ.ស.ប និងលោក Hans Corell ទីប្រឹក្សាច្បាប់របស់ អ.ស.ប ទាំងពីរនាក់ បានបញ្ជាក់ពីកង្វល់យ៉ាងច្បាស់លាស់ទៅកាន់រាជរដ្ឋាភិបាលកម្ពុជាថា ឥឡូវនេះក្រុមនោះគឺទូលំទូលាយពេក[24]។ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ សភាជាតិកម្ពុជាបានអនុម័តច្បាប់ អ.វ.ត.ក ជាមួយនឹងពាក្យថា "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត"[25]។ ជាការគួរឱ្យកត់សម្គាល់ លោក Scheffer បានរំឭកឡើងវិញថា៖

> [...] ដោយធ្លាប់ជាផ្នែកនៃការចរចាអស់ជាច្រើនឆ្នាំ ខ្ញុំដឹងថាមិនមានសម្បទានណាមួយដោយអ្នកចរចារបស់ អ.ស.ប នោះទេ ក្នុងការបកស្រាយភាសាស្ដីពីយុត្តាធិការបុគ្គលដើម្បីកម្រិតក្រុមជនសង្ស័យ ឱ្យនៅត្រឹមតែបុគ្គលជាក់លាក់ចំនួនប្រាំនាក់នោះទេ[26]។

16. សរុបសេចក្ដីមក ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក បង្ហាញថា ទាំងចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និងទាំងរបស់ អ.ស.ប នៅពេលធ្វើកិច្ចព្រមព្រៀង អ.វ.ត.ក គឺថា "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទបើកចំហរដែលសមាជិកភាពរបស់ពួកគេត្រូវ បានកំណត់ដោយសហព្រះរាជអាជ្ញា និងចៅក្រមនៃ អ.វ.ត.ក តែប៉ុណ្ណោះ ដោយផ្អែកទៅលើភ័ស្តុតាងទាំងមូល និងបំពេញកិច្ចដោយឯករាជ្យ មិនស្ថិតក្រោមការណែនាំណាមួយឡើយ។

### គ. ឥឡូវនេះ មិនមានភាគីណាមួយនៃកិច្ចព្រមព្រៀង អ.វ.ត.ក អាចផ្លាស់ប្ដូរជាឯកតោភាគីនូវវិសាលភាពនៃយុត្តាធិការបុគ្គលបានទេ

17. បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ បានអះអាងថា "ស្ថាបនិកតុលាការអន្តរជាតិ អាចមានឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ ដោយមិនធ្វើឱ្យប៉ះពាល់ដល់អនាគតិ និងឯករាជ្យភាពរបស់តុលាការឡើយ" ហើយថា "ការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺរាជរដ្ឋាភិបាលកម្ពុជាកំពុងតែដើរតួដូចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY ICTR និង SCSL អញ្ចឹងដែរ"[27]។ ផ្អែកលើការដកស្រង់នេះ បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ "ជម្រុញឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអង្គ

[24] អត្ថបទរបស់ Scheffer ទំព័រទី ៥-៨។

[25] អត្ថបទរបស់ Scheffer ទំព័រទី ៨។

[26] អត្ថបទរបស់ Scheffer ទំព័រទី ១០។

[27] ឯកសារ **D360/8/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៩០។

ជំនុំជម្រះ ឲ្យធ្វើសកម្មភាពស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមស្មារតីច្បាប់ អ.វ.ត.ក"[28] ស្តីពីយុត្តាធិការបុគ្គល។

18. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ផ្អែកអំណះអំណាងនេះលើសេចក្តីសម្រេចចិត្តរបស់ ក្រុមប្រឹក្សាសន្តិសុខលេខ ១៥០៣ និង ១៥៣៤ ដែលត្រូវបានអនុម័តប្រមាណជា ១០ឆ្នាំ ក្រោយ ការបង្កើតតុលាការ ICTY និងតុលាការ ICTR និងទាក់ទងទៅនឹងការបញ្ចប់របស់តុលាការពីរនេះ។ សេចក្តីសម្រេចចិត្តទាំងនេះបានបង្គាប់ឲ្យតុលាការ ICTY និងតុលាការ ICTR ផ្តោតកិច្ចប្រឹងប្រែងរបស់ពួកគេទៅលើ "មេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យថាជាអ្នកទទួលខុសត្រូវ ខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម" និងបញ្ជូនសំណុំរឿងផ្សេងទៀតទៅយុត្តាធិការជាតិ ដើម្បីសម្រេចបានតាមផែនការបញ្ចប់របស់តុលាការ[29]។ តាមរយៈនេះ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ សន្និដ្ឋានថា "រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាស្ថាបនិកមួយនៃកិច្ចព្រមព្រៀង អាចមានឥទ្ធិពលលើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ" ហើយថា "វិធីសាស្ត្រដែលអាចទទួលយកបានសម្រាប់ការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ គឺការកម្រិតវិសាលភាពយុត្តាធិការបុគ្គល"[30]។

19. នេះគឺជាសទិសភាពមិនត្រឹមត្រូវ។ តុលាការ ICTY និងតុលាការ ICTR ត្រូវបានបង្កើតឡើងពីដំបូងដោយសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ[31] ហើយនៅក្នុងការអនុវត្តតាមសេចក្តីសម្រេចចិត្តលេខ ១៥០៣ និង ១៥៣៤ ទាក់ទងនឹងផែនការបញ្ចប់ ដោយមានកិច្ចធានាដំណើរការនីតិវិធីតែមួយដូចគ្នាទាំងអស់ ដូចដែលវាមាននៅពេលដែលវាត្រូវបានបង្កើតជាតុលាការ *មិនអចិន្ត្រៃយ៍*ទាំងនេះពីដំបូង។ សមាជិកទាំងអស់នៃក្រុមប្រឹក្សាសន្តិសុខមានសិទ្ធិចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលលើសេចក្តីសម្រេចលេខ ១៥០៣ និង ១៥៣៤ និងផ្តល់យោបល់លើអង្គសេចក្តីនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រជ្រើសរើសសំណុំរឿងរបស់តុលាការ។ សមាជិកម្នាក់ៗ

---

[28] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៩០។

[29] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៨៧។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ១៥០៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ("សេចក្តីសម្រេចចិត្តលេខ ១៥០៣") S/RES/១៥០៣ (ឆ្នាំ២០០៣) ទំព័រ ១-២។ សេចក្តីសម្រេចចិត្តលេខ ១៥៣៤ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ("សេចក្តីសម្រេចចិត្តលេខ ១៥០៤") S/RES/១៥០៤ (ឆ្នាំ២០០៤) កថាខណ្ឌ ៤-៥។

[30] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៨៦។

[31] សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ S/RES/៨២៧ (ឆ្នាំ១៩៩៣) [ការបង្កើតឲ្យមានតុលាការ ICTY]។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៩៥៥ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ S/RES/៩៥៥ (ឆ្នាំ១៩៩៤) [ការបង្កើតឲ្យមានតុលាការ ICTR]។

នៃក្រុមប្រឹក្សាសន្តិសុខ នៅពេលនោះមានសិទ្ធិបោះឆ្នោតលើសេចក្តីសម្រេចចិត្តដែលបានដាក់ស្នើឡើង មុនពេលពួកវាត្រូវបានអនុម័ត។ ជាក់ស្តែង បើសិនជាសមាជិកណាតែម្នាក់នៃក្រុមប្រឹក្សាសន្តិសុខបានបង្ហាញទស្សនៈថា តុលាការ *មិនអចិន្ត្រៃយ៍*នេះគួរផ្លាស់ប្តូរយុទ្ធសាស្ត្រជ្រើសរើសសំណុំរឿងរបស់ខ្លួន ដើម្បីឲ្យមានអានុភាពណាមួយនោះ ជាដំបូងវាគួរតែឆ្លងកាត់ដំណើរការពិភាក្សាដេញដោល និងមានការបោះឆ្នោតមួយដើម្បីអនុម័តសេចក្តីសម្រេចចិត្តជាផ្លូវការ។

20. ក្នុងករណី អ.វ.ត.ក នេះ សទិសភាពដ៏សមស្របទៅនឹងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខដែលបានបង្កើតតុលាការ *មិនអចិន្ត្រៃយ៍* នោះគឺកិច្ចព្រមព្រៀង អ.វ.ត.ក ដែលត្រូវបានអនុម័ដោយ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីការចរចាដែលក្នុងនោះភាគីទាំងពីរគឺជាសមភាគី។ កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "នៅក្នុងករណីចាំបាច់មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មបែបនេះត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ"[32]។ បទប្បញ្ញត្តិនេះបញ្ជាក់ច្បាស់ថា ការកែប្រែណាមួយក្នុងគោលនយោបាយពាក់ព័ន្ធនឹងបញ្ហានានាដែលបានលើកឡើងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក (ដែលរួមទាំង យុត្តាធិការបុគ្គលផង) ត្រូវតែអនុម័តដោយភាគី *ទាំងពីរ* តាមរយៈកិច្ចពិភាក្សាដែលក្នុងនោះភាគី *ទាំងពីរ* ចូលរួម។ មកទល់ពេលនេះ ទាំងរាជរដ្ឋាភិបាលកម្ពុជា ឬ អ.ស.ប មិនបានស្វែងរកឲ្យមានការកែប្រែបទប្បញ្ញត្តិទាក់ទងទៅនឹងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក នេះទេ។

21. ការទទួលស្គាល់សិទ្ធិរបស់ អ.ស.ប ក្នុងការចូលរួមកែប្រែគោលនយោបាយស្តីពីយុត្តាធិការបុគ្គលមិនបានធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជានោះទេ៖ រដ្ឋទាំងឡាយមានអំណាចចូលរួមក្នុងកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត ហើយការដែលបានធ្វើដូច្នេះ រដ្ឋនីមួយៗគិតចាប់ពីរដ្ឋធំបំផុតដល់រដ្ឋតូចបំផុត មានកាតព្វកិច្ចអនុវត្តតាមកិច្ចព្រមព្រៀង លុះត្រាតែ និងរហូតទាល់តែពួកវាត្រូវបានធ្វើវិសោធនកម្ម រដ្ឋនោះដកខ្លួនចេញជាផ្លូវការ។ ក្រោយពីបានផ្តល់សច្ចាប័នកិច្ចព្រមព្រៀង អ.វ.ត.ក ភាគីទាំងពីជាប់កាតព្វកិច្ចដោយលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងនេះ ហើយមិនមានភាគីណាមួយអាចកែប្រែអត្ថន័យនៃលក្ខខណ្ឌទាំងនោះតាមរយៈសេចក្តីប្រកាសគោលនយោបាយជាឯកតោភាគីធ្វើឡើងក្រោយពេលអនុម័តកិច្ចព្រមព្រៀងនេះបានឡើយ។[33] ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាលែងមានបំណងផ្តល់ការទទួលខុសត្រូវឲ្យ អ.វ.ត.ក នាំយកជនទាំងឡាយដែលទទួលខុស

---

[32] កិច្ចព្រមព្រៀប អ.វ.ត.ក មាត្រា ២(៣)។

[33] ជាការសន្មត វាច្បាស់ណាស់ថា ប្រសិនបើមន្ត្រីអង្គការសហប្រជាជាតិ លើកឡើងថា ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ឧទាហរណ៍ រួមមាន កម្មាភិបាលខ្មែរក្រហមណាមួយនៅក្នុងកម្រិតណាមួយដែលបានសម្លាប់មនុស្សលើសពី ២៥នាក់ ចំណុចនេះនឹងមិនមែនជាមូលដ្ឋានដ៏គួរឲ្យជឿជាក់សម្រាប់ការអះអាងថា នោះគឺជានិយមន័យត្រឹមត្រូវនៃពាក្យនេះ។

ត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកជំនុំជម្រះ រដ្ឋាភិបាលនេះអាចស្នើសុំដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ[34] ឬធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក ដោយមានការឯកភាពពី អ.ស.ប។ មិនមានការព្យាយាមណាមួយត្រូវបានធ្វើឡើងដើម្បីធ្វើដូច្នេះ ឡើយមកទល់ពេលនេះ។ ហេតុដូច្នេះ វិសាលភាពយុត្តាធិការបុគ្គលដែលមានចែងក្នុងកិច្ចព្រម ព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក គឺជាប្រភពតែមួយគត់ ដែល អ.ប.ជ អាចពិចារណា។

22. ខុសពី "ឥទ្ធិពល" របស់រាជរដ្ឋាភិបាលកម្ពុជា "លើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[35] សេចក្តីសម្រេចចិត្តលេខ ១៥០៣ និង ១៥៣៤ មិនមានន័យថាមានឥទ្ធិពលណាមួយលើបញ្ហាថាតើ សំណុំរឿងមួយត្រូវបានចោទប្រកាន់ ឬយ៉ាងណានោះទេ ផ្ទុយទៅវិញ ពួកវាមានឥទ្ធិពលតែទៅលើតុលាការដែលជំនុំជម្រះសំណុំរឿងជាក់លាក់នោះប៉ុណ្ណោះ។ សេចក្តីសម្រេចចិត្តលេខ ១៥០៣ បានណែនាំឲ្យតុលាការ *មិនអចិន្ត្រៃយ៍*ផ្តោតលើសំណុំរឿងប្រឆាំងនឹង "មេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យថាជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ប៉ុន្តែសំណុំរឿងផ្សេងទៀតមិនត្រូវបានច្រានចោលទេ - ផ្ទុយទៅវិញ ពួកវាត្រូវ "ផ្ទេរ [បានផ្ទេរ] [...] ទៅតុលាការជាតិដែលមានសមត្ថកិច្ច"[36]។ តាមពិតនោះ ក្រុមប្រឹក្សាសន្តិសុខបានគូសបញ្ជាក់ថា ការអនុម័តសេចក្តីសម្រេចចិត្តលេខ ១៥០៣ មិនមានបំណងកាត់បន្ថយចំនួនមនុស្សដែលត្រូវស៊ើបអង្កេត និងជំនុំជម្រះចំពោះឧក្រិដ្ឋកម្មឃោរឃៅក្នុងទ្រង់ទ្រាយធំទេៈ សេចក្តីសម្រេចចិត្តនេះចែងយ៉ាងច្បាស់ថា ផែនការបញ្ចប់របស់តុលាការ "មិនត្រូវប៉ះពាល់ដល់កាតព្វកិច្ចរបស់ប្រទេសរ្វាន់ដា និងប្រទេសទាំងឡាយនៃអតីតយូហ្គោស្លាវី ក្នុងការស៊ើបអង្កេតជនជាប់ចោទទាំងនោះ ដែលសំណុំរឿងរបស់ពួកគេមិនត្រូវបានជំនុំជម្រះដោយតុលាការ ICTR ឬតុលាការ ICTY និងត្រូវចាត់វិធានការសមស្រប ទាក់ទងនឹងការបញ្ជូនរឿងទៅជុំជម្រះ និងការកាត់ទោស"[37]។ សេចក្តីសម្រេចចិត្តលេខ ១៥០៣ និង ១៥៣៤ មិនលើកទឹកចិត្តឲ្យមាននិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការតុលាការ *មិនអចិន្ត្រៃយ៍*នោះទេ ផ្ទុយទៅវិញពួកវាគ្រាន់តែបែងចែកកិច្ចការស៊ើបអង្កេត និងការចោទប្រកាន់ រវាងតុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការជាតិប៉ុណ្ណោះ។

23. បន្ថែមលើនេះ ក្រុមប្រឹក្សាសន្តិសុខគោរពឯករាជ្យភាពតុលាការ តាមរយៈការមិនបង្ហាញទស្សនៈណាមួយលើការសន្និដ្ឋានដ៏សមស្របលើសំណុំរឿងជាក់លាក់ណាមួយនៅតុលាការ ICTY ឬ

---

[34] អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់អនុសញ្ញា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ មាត្រា ៥៤, ៥៦។

[35] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ ៨៦។

[36] សេចក្តីសម្រេចចិត្តលេខ ១៥០៣ ទំព័រ ១-២។

[37] សេចក្តីសម្រេចចិត្តលេខ ១៥០៣ ទំព័រ២។

ICTY នោះទេ។ ទោះបីជា ក្រុមប្រឹក្សា*ពិតជាបាន* កំណត់លក្ខន្តិកៈ “មេដឹកនាំជាន់ខ្ពស់ដែលត្រូវបានសង្ស័យថាជាជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម” ជាការធ្វើតេស្តថាតើសំណុំរឿងមួយណាគួរទុក ក្រុមប្រឹក្សាមិនដែលបង្ហាញទស្សនៈណាមួយថាតើ សំណុំរឿងជាក់លាក់ណាមួយបំពេញតាមការធ្វើតេស្តនោះទេ។ ការអនុវត្តការធ្វើតេស្តនេះគឺជាឆន្ទានុសិទ្ធិឯករាជ្យរបស់ចៅក្រមនៃតុលាការ ICTY និង ICTR។

24. កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក តម្រូវថា ចៅក្រម អ.វ.ត.ក មានសេរីភាពក្នុងការអនុវត្តឆន្ទានុសិទ្ធិដោយឯករាជ្យដូចគ្នានេះដែរ។ ក្នុងផ្នែកមួយនៃ មាត្រា ១០*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងថា “ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ”។ ការហាមឃាត់មិនឱ្យចៅក្រមទទួលការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពខាងក្រៅណាមួយក៏មានចែងក្នុងមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែរ។

25. លក្ខខណ្ឌតម្រូវឱ្យមានតុលាការឯករាជ្យក៏មានចែងនៅក្នុងលិខិតុបករណ៍ និងសេចក្តីថ្លែងការសិទ្ធិមនុស្សជាច្រើនផងដែរ អំពីការអនុវត្តល្អបំផុត និងបទដ្ឋានអប្បបរិមា រួមមានសេចក្តីថ្លែងការណ៍ក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពរបស់តុលាការ ដែលត្រូវបានប្រកាស់ឱ្យប្រើជាផ្លូវការដោយសមាគមច្បាប់អាស៊ីនិងប៉ាស៊ីហ្វិក[38] ក្រមទីក្រុងញូដេលីស្តីពីបទដ្ឋានអប្បបរិមានៃឯករាជ្យភាពតុលាការ ដែលបានអនុម័តដោយគណៈមេធាវីអន្តរជាតិ[39] និងគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពតុលាការត្រូវបានយល់ព្រមដោយមហាសន្និបាត អ.ស.ប[40]។ គោលការណ៍ទាំងនេះតម្រូវថា “រដ្ឋមន្ត្រីរបស់រដ្ឋាភិបាលមិនត្រូវធ្វើអនុវត្តការដាក់សម្ពាធលើចៅក្រមក្នុងរូបភាពណាមួយឡើយ ទោះបីជាដោយផ្ទាល់ ឬមិនផ្ទាល់ និងមិនត្រូវធ្វើសេចក្តីថ្លែងការណ៍ណាដែលប៉ះពាល់មិនល្អដល់ឯករាជ្យភាពរបស់ចៅក្រមជាលក្ខណៈបុគ្គល ឬតុលាការទាំងមូលនោះឡើយ”[41]។

---

[38] សេចក្តីថ្លែងការក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពតុលាការ នៅក្នុងតំបន់ Lawasia, សមាគមច្បាប់សម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧ មាត្រា៣(ក), ៤-៥។

[39] ក្រមញូដេលីស្តីពីបទដ្ឋានអប្បបរិមានៃតុលការឯករាជ្យ, សមាគមគណៈមេធាវីអន្តរជាតិ ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៨២ (“ក្រមញូដេលី”) មាត្រា ១៦។

[40] គោលការជាមូដ្ឋានស្តីពីឯករាជ្យភាពតុលាការ ដែលត្រូវបានអនុម័តយល់ព្រមដោយសេចក្តីសម្រេចចិត្តមហាសន្និបាតលេខ ៤០/៣២ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ ៤០/១៤៦ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ កថាខណ្ឌ ១-២, ៤។

[41] ក្រមញូដេលី មាត្រា១៦។

26. គោលការណ៍ជាមូលដ្ឋាននៃនីតិរដ្ឋគឺថា ទោះបីជាអង្គនីតិបញ្ញត្តិ ឬអង្គនីតិប្រតិបត្តិទទួលខុសត្រូវក្នុង*ការធ្វើច្បាប់* តាមរយៈ នីតិកម្ម បទបញ្ញាប្រតិបត្តិ និងអនុសញ្ញា ក៏ដោយ មានតែតុលាការមួយគត់ដែលសម្រេច*ថាតើត្រូវអនុវត្តច្បាប់នោះ*ទៅលើសំណុំរឿងនីមួយៗដោយរបៀបណា។ ក្នុងប្រព័ន្ធគ្រប់គ្រងដោយនីតិរដ្ឋ ឯករាជ្យភាពតុលាការត្រូវបានគោរព។ ចៅក្រមត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនផ្អែកលើច្បាប់ ភ័ស្តុតាង និងការវិនិច្ឆ័យ និងសតិសម្បជញ្ញៈផ្ទាល់ខ្លួនរបស់ពួកគេ ដោយមិនទទួលការណែនាំពីរដ្ឋាភិបាល ឬប្រភពខាងក្រៅណាមួយឡើយ។

**ឃ. សេចក្តីសម្រេចតុលាការឯករាជ្យលើសំណុំរឿង ០០៣, ០០៤ និង ០០៤/២ នឹងលើកកម្ពស់ទាំងយុត្តិធម៌ និងការផ្សះផ្សា**

27. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ លើកឡើងថា បុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក តម្រូវថា "ត្រូវថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"" អះអាងថា សំណុំរឿង០០១ និង ០០២ បាននាំយុត្តិធម៌មកជូនជនរងគ្រោះរួចហើយ និងបកស្រាយថា ការបន្តកិច្ចដំណើរការនីតិវិធីប្រឆាំង អោ អាន នឹងប៉ះពាល់ដល់ការផ្សះផ្សាជាតិ[42]។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មិនបានផ្តល់ភ័ស្តុតាងណាមួយបញ្ជាក់ថា ការនាំខ្លួន អោ អាន ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលរូបគាត់ត្រូវបានចោទប្រកាន់នេះ នឹងប៉ះពាល់ដល់ការផ្សះផ្សាជាតិដោយរបៀបណានោះទេ។ ផ្ទុយទៅវិញ វាច្បាស់ណាស់ថា ការនាំខ្លួន អោ អាន មកសវនាការដើម្បីឆ្លើយតបទៅនឹងភ័ស្តុតាងដ៏គួរឱ្យជឿជាក់អំពីតួនាទីរបស់គាត់ក្នុងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប៉ះពាល់ដល់ប្រជាជនកម្ពុជារាប់ម៉ឺននាក់ នឹងជួយឱ្យសម្រេចបានយុត្តិធម៌ក្នុងកម្រិតណាមួយសម្រាប់ជនរងគ្រោះបន្ថែមទៀត ដូច្នេះវានឹងដោះស្រាយក្តីកង្វល់នានានៅក្នុងបុព្វកថានេះ។

28. ទីមួយ ជាការកត់សម្គាល់ដ៏មានសារៈសំខាន់ថា គ្មានចំណុចណាមួយនៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក ចង្អុលបង្ហាញថា វាត្រូវបានរំពឹងទុកជាផ្នែកមួយនៃការធ្វើតេស្តសម្រាប់យុត្តាធិការបុគ្គលនោះឡើយ។ កង្វល់អំពីការផ្សះផ្សាជាតិត្រូវបានដោះស្រាយតាមរយៈការដាក់កម្រិតវិសាលភាពនៃយុត្តាធិការបុគ្គលត្រឹមមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត - ជាក្រុមតូចមួយធៀបទៅនឹងក្រុមខ្មែរក្រហមទាំងមូល។ ដូចដែលក្រុមអ្នកជំនាញ អ.ស.ប ស្តីពីកម្ពុជាបានលើកឡើងនៅក្នុងរបាយការណ៍របស់ពួកគេផ្ញើទៅកាន់អគ្គលេខាក្នុងឆ្នាំ១៩៩៩ ថា "ការទទួលខុសត្រូវចំពោះអតីតកាល និងការផ្សះផ្សាជាតិសម្រាប់អនាគត តាមពិតនោះមិនមែន

[42] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៩៤-៩៦។

ជារឿងផ្ទុយគ្នា ឬជាគោលដៅប្រគួតប្រជែងឡើយ។ [...] ប្រសិនបើយុត្តិធម៌កើតមានប្រកប ដោយវេទយិតភាពចំពោះស្ថានភាពផ្ទាល់របស់ប្រទេសមួយ នោះការទទួលខុសត្រូវ និងការ ផ្សះផ្សាជាតិ តាមពិតជាការបំពេញបន្ថែម និងមិនអាចញែកចេញពីគ្នាបាន"[43]។

29. សំខាន់ជាងនេះទៀត មិនមានសញ្ញាណណាមួយដែលថា សេចក្ដីសម្រេចរបស់តុលាការឯករាជ្យនៃ សំណុំរឿង០០៤/២, ០០៤ និង ០០៣ លើអង្គសេចក្ដី - ទោះបីសម្រេចថាយ៉ាងដូចម្ដេចក៏ដោយ- នឹងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខរបស់ប្រទេសកម្ពុជានោះទេ។ ដូចដែល ស.ព.អ បានសង្កេតពីមុនមក សេចក្ដីសម្រេចនៃសំណុំរឿង ០០១ និង ០០២ ដោយមានការផ្ដន្ទាទោសដាក់ ពន្ធនាគារមួយជីវិត មិនបានប៉ះពាល់ជាអវិជ្ជមានដល់ការផ្សះផ្សាជាតិ ឬសន្តិភាពនោះទេ។ ផ្ទុយទៅវិញ ការផ្ដន្ទាទោសនេះទទួលបានការស្វាគមន៍យ៉ាងទូលំទូលាយទាំងនៅក្នុង និងនៅក្រៅ ប្រទេសកម្ពុជា ហើយការសម្រេចផ្ដន្ទាទោសនេះបាន *លើកកំពស់* ការផ្សះផ្សាជាតិ[44]។ សំណុំរឿង ទាំងនេះ ជាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទទាំងអ្នកដែលមានឋានៈទាបជាង អោ អាន (ឌុច) និងទាំងអ្នកដែលមានឋានៈខ្ពស់ជាងគាត់នៅក្នុងឋានានុក្រម ប.ក.ក (នួន ជា និង ខៀវ សំផន)។ បន្ថែលលើនេះ មិនមានប្រតិកម្មអវិជ្ជមានពីសាធារណជនទៅនឹងការប្រកាសថា អោ អាន និង មាស មុត ត្រូវបានចោទប្រកាន់ ឬថា យឹម ទិត្យ កំពុងស្ថិតក្រោមការស៊ើបអង្កេតនោះឡើយ[45] ហេតុដូច្នេះមិនមានហេតុផលណាត្រូវជឿថា ការបញ្ជូន អោ អាន ទៅជំនុំជម្រះនឹងគំរាមកំហែង ដល់ការផ្សះផ្សាជាតិនោះទេ។ ជាងនេះទៀត កម្ពុជាបច្ចុប្បន្ននេះទទួលបានសន្តិភាព និងស្ថេរភាព ជាងពីរទសវត្សមកហើយ[46]។ មិនមានក្រុមប្រដាប់អាវុធកំពុងប្រើអំណាចលើទឹកដីកម្ពុជានោះទេ។ ខ្មែរក្រហមលែងមានអត្ថិភាពទៀតហើយ ដោយសារតែអង្គការយោធា ឬនយោបាយ អតីតកម្មា

[43] របាយការណ៍ក្រុមអ្នកជំនាញ អ.ស.ប កថាខណ្ឌ ៣។

[44] សំណុំរឿង០០៤-ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ("ដីកាសន្និដ្ឋានស្ថាពរសំណុំរឿង០០៤ របស់ ស.ព.អ") កថាខណ្ឌ ១១៥១។

[45] សំណុំរឿង០០៤-ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពរសំណុំរឿង០០៤ របស់ ស.ព.អ កថាខណ្ឌ១១៥២។

[46] សូម្បីតែក្នុងឆ្នាំ១៩៩៨ ក្នុងពេលដំណើរទស្សនកិច្ចរបស់ក្រុមអ្នកជំនាញមកកាន់កម្ពុជា សមាជិកតំណាងឱ្យសាធារណជន កម្ពុជា និងរដ្ឋាភិបាល មិនបានបង្ហាញការគាំទ្រអាទិភាពដាច់ខាតនៃបញ្ហាសន្តិសុខជាងផលប្រយោជន៍យុត្តិធម៌នោះទេ។ ដូចដែល ក្រុមអ្នកជំនាញបានសង្កេតថា "ចំពោះការយល់ឃើញរបស់សាធារណជន ក្រុមអ្នកជំនាញពិតជាបានឮថាក្នុងចំណោម សាធារណជនទាំងក្នុង និងក្រៅរដ្ឋាភិបាលពិតជាចង់បានសន្តិភាពយ៉ាងខ្លាំង ប៉ុន្តែគ្មាននរណាម្នាក់លើកឡើងថា សន្តិភាព និង ការជំនុំជម្រះមិនអាចបង្រួបបង្រួមគ្នាបាននោះទេ ឬថាប្រជាជនកម្ពុជាមើលឃើញសន្តិភាពជាការជំនួសឱ្យយុត្តិធម៌នោះទេ"។ *សូមមើល*របាយកាណ៍ក្រុមអ្នកជំនាញ អ.ស.ប កថាខណ្ឌ ៩៩។

ភិបាល បច្ចុប្បន្ននេះចាស់អស់ហើយ របបប៉ុលពតត្រូវបានគេដេវប្រមាថស្ទើតែទូទាំងសកលលោក និងគ្មានភស្តុតាងណាបង្ហាញពីការគាំទ្រណាមួយចំពោះការកើតមានឡើងវិញនៃចលនានេះទេ[47]។ ការបះបោរប្រដាប់អាវុធរបស់ខ្មែរក្រហមឡើងវិញ មិនមែនជាភវនីយភាពក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះទេ។

30. ផ្ទុយទៅវិញ មានសញ្ញាណច្បាស់លាស់ថា ជនរងគ្រោះមិនឯកភាពទៅនឹងការអះអាងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ដែលថា មិនចាំបាច់មានយុត្តិធម៌បន្ថែមទៀតនោះទេ បន្ទាប់ពីការជំនុំជម្រះសំណុំរឿង០០១ និង ០០២។ ចាប់តាំងពីកើតមាន អ.វ.ត.ក មក ការសិក្សាស្រាវជ្រាវជាច្រើនទាក់ទងនឹងទស្សនៈរបស់សាធារណជនកម្ពុជាអំពី អ.វ.ត.ក ត្រូវបានបោះពុម្ពផ្សាយ។ ទោះបីជាការសិក្សាស្រាវជ្រាវទាំងនេះខុសគ្នាទៅលើវិធីសាស្ត្រ ក្រុមគោលដៅ និងសំណួរសិក្សាស្រាវជ្រាវក៏ដោយ ក៏ការសិក្សាស្រាវជ្រាវទាំងអស់នេះបានបង្ហាញថា សាធារណជនកម្ពុជាមានចំណាប់អារម្មណ៍ខ្លាំងចង់ឃើញសំណុំរឿងដែលនៅសល់ដំណើរការទៅមុខ។

31. ការសិក្សាស្រាវជ្រាវចុងក្រោយត្រូវបានបោះពុម្ពផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ និងត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលសិក្សាទំនាស់ Marburg (Marburg Center for Conflict Studies) មជ្ឈមណ្ឌលភ្នំពេញសម្រាប់ការសិក្សាអំពីច្បាប់មនុស្សធម៌ (Phnom Penh Center for the Study of Humanitarian Law) និង Swiss Peace ("ការសិក្សាដោយ Marburg")[48]។ ការសិក្សានេះផ្តោតលើការចូលរួមរបស់ជនរងគ្រោះ ដូច្នេះវាបានស្ទង់មតិជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន ៤៣៩នាក់ ដែលបានជ្រើសរើសព្រាវចេញពីក្រុមដែលបានកំណត់ជាមុនចំនួនបួនក្រុម[49]។ ជាការកត់សម្គាល់ នៅពេលសួរថាតើ អ.វ.ត.ក គួរដោះស្រាយសំណុំរឿង ០០៣ និង

[47] សំណុំរឿង០០៤-ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពរសំណុំរឿង០០៤ របស់ ស.ព.អ កថាខណ្ឌ១១៥៣។

[48] Williams, T., និងគូកន "យុត្តិធម៌ និងការផ្សះផ្សាសម្រាប់ជនរងគ្រោះខ្មែរក្រហម? ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការយុត្តិធម៌អន្តរកាលកម្ពុជា" Marburg: មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីទំនាស់។ ភ្នំពេញ៖ មជ្ឈមណ្ឌលសក្សាច្បាប់មនុស្សធម៌។ Bern: swisspeace, វិច្ឆិកា ២០១៨ ("ការសិក្សាដោយ Marburg")។ ការប្រមូលទិន្នន័យសម្រាប់ការសិក្សាចាប់ពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ (*សូមមើល*ការសិក្សាដោយ Marburg ទំព័រ ២៣)។

[49] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ដែលមានក្រុមទីមួយ មានចំនួនជាងពាក់កណ្តាលនៃចំនួនអ្នកឆ្លើយតប។អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះត្រូវបានបែងចែកជាក្រុមតូចៗចំនួនប្រាំបីក្រុម តាមកម្រិតប្រែប្រួលនៃការចូលរួមរបស់ពួកគេក្នុងកិច្ចដំណើរការនីតិវិធី និងអ្នកខ្លះជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ និង ០០៤ (សំណុំរឿង០០៤ ត្រូវបានប្រើជាពាក្យទូលាយគ្របដណ្តប់ទៅលើសំណុំរឿង០០៤/២ ផង)។ ក្រុមទីពីរមានអ្នកដាក់បណ្តឹង *គឺជា*បុគ្គលដែលបានចុះឈ្មោះជាមួយនឹងតុលាការ ពីព្រោះពួកគេបានផ្តល់ព័ត៌មាន ប៉ុន្តែពួកគេមិនបានដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ក្រុមទីបីមានជនរងគ្រោះ ដែលបានចូលរួមក្នុងសកម្មភាពអង្គការក្រៅរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងយុត្តិធម៌អន្តរ

០០៤ ឬទេ (រួមទាំងសំណុំរឿង ០០៤/២ ផង) អ្នកឆ្លើយតបចំនួន ៨០,២ ភាគរយគាំទ្រឱ្យសំណុំរឿងទាំងនេះដំណើរការទៅមុខ។ ហេតុផលសំខាន់ចំនួនប្រាំដែលបានដកស្រង់ ចាប់ពីញឹកញាប់ច្រើនបំផុត ទៅតិចបំផុតគឺ (១) វានឹងផ្តល់ឱ្យអ្នកឆ្លើយនូវអារម្មណ៍ថាមានយុត្តិធម៌ (២) វាមានន័យថា មានយុត្តិធម៌សម្រាប់ជនរងគ្រោះទូទៅ (៣) វាមានន័យថា មេដឹកនាំខ្មែរក្រហមមិនអាចគេចវេះពីតុលាការបានទេ (៤) វានឹងផ្តល់ការពិតជាងមុនអំពីរបបខ្មែរក្រហម និង (៥) វានឹងនាំមកនូវយុត្តិធម៌ដល់ប្រទេសកម្ពុជា[50]។ មានអ្នកឆ្លើយតែ ២,៧៧ ភាគរយប៉ុណ្ណោះគិតថាសំណុំរឿងទាំងនេះមិនគួរដំណើរការទៅមុខ ព្រោះវាអាចនាំឱ្យមានជម្លោះ ប៉ុន្តែអ្នកធ្វើការសិក្សាស្រាវជ្រាវទាំងនេះជឿជាក់ថា ការភ័យខ្លាចអំពីចលាចល អាចជាប់ពាក់ព័ន្ធទៅនឹង "វោហាសាស្រ្តចចេសរឹងរូសរបស់រដ្ឋាភិបាលដែលបង្ហាញពីចេតនាមិនគាំទ្រឱ្យមានសំណុំរឿងបន្ថែមទៀតនៅ អ.វ.ត.ក ក្រៅពីសំណុំរឿង ០០២"[51]។

32. អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សង្គមបើកចំហរ (Open Society Justice Initiative) បានធ្វើការសិក្សាមួយពីខែតុលា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤ ("ការសិក្សារបស់ OSJI") ដែលផ្តោតលើផលប៉ះពាល់របស់ អ.វ.ត.ក លើប្រជាជនកម្ពុជាសាមញ្ញ[52]។ ទំហំសំណាកអ្នកឆ្លើយតបដែលបានសម្ភាសមានចំនួនតិចជាងការសិក្សាដោយ Marburg ប៉ុន្តែវាមានលក្ខណៈចម្រុះជាងដែលរួមមាន ជនរងគ្រោះ/អ្នករស់រានមានជីវិត ជនជាប់ចោទ ជនដៃដល់ អ្នកឃើញហេតុការណ៍ និងយុវជន[53]។ ក្នុងពេលប្រមូលទិន្នន័យ ក្នុងចំណោមអ្នកឆ្លើយតបចំនួន ៤៩នាក់ ដែលត្រូវបានសួរ និងបានដឹងអំពីសំណុំរឿង០០៣ និង ០០៤ មាន ២៩នាក់ ចង់ឱ្យសំណុំរឿងទាំងនេះដំណើរការ

---

កាលក្នុងប្រទេសកម្ពុជា។ ក្រុមទីបួន មានបុគ្គលដែលមិនចូលរួមក្នុងកិច្ចដំណើរការ អ.វ.ត.ក និងគម្រោងរបស់អង្គការក្រៅរដ្ឋាភិបាល។ ខណៈដែលទាំងអស់គ្នា លើកលែងតែអ្នកឆ្លើយពីរនាក់ចេញ ចាត់ទុកខ្លួនឯងថាជាជនរងគ្រោះក្នុងរបបខ្មែរក្រហមនោះ អាយុជាមធ្យមរបស់អ្នកឆ្លើយតបគឺ ៦២.៤ ឆ្នាំ។ *សូមមើល* ការសិក្សាដោយ Marburg ទំព័រ ១៩, ២១-២២, ២៨។

[50] ការសិក្សាដោយ Marburg ទំព័រ៦៣។ *កត់សម្គាល់*ថាអ្នកឆ្លើយតបត្រូវបានអនុញ្ញាតឱ្យផ្តល់ព័ត៌មានលើសពីមួយ។

[51] ការសិក្សាដោយ Marburg ទំព័រ ៦២-៦៣។ មានតែ១៤% ក្នុងចំណោម ១៩.៨% នៃអ្នកឆ្លើយតបដែលមិនគាំទ្រសំណុំរឿង០០៣ និង ០០៤ ដែលបានដកស្រង់ហេតុផលនេះ មានចំនួនតែ ២.៧៧% នៃក្រុមអ្នកឆ្លើយតបទាំងមូល។

[52] Ryan, H. និង McGrew, L., "ការប្រព្រឹត្ត និងទស្សនៈ៖ ផលប៉ះពាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ញូយ៉ក៖ អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សង្គមបើកចំហរ ២០១៦ ("ការសិក្សាដោយ OSJI") ទំព័រ១២៦-១២៧ យោងចុងទំព័រ ២១០។

[53] ការសិក្សាដោយ OSJI ទំព័រ១២៦-១២៧ យោងចុងទំព័រ២១០។ *សម្គាល់* ថាអ្នកឆ្លើយតបយកចេញមកពីបញ្ជីទំនាក់ទំនង OSJI ដែលមានស្រាប់ក្នុងប្រទេសកម្ពុជា ហើយហេតុនេះ ក្រុមសំណាកមិនព្រាវៗទេ។ ក្នុងចំណោមអ្នកឆ្លើយតប ១២២នាក់ មានជនជាតិកម្ពុជាចំនួន ១០៩នាក់។

ទៅមុខ ចំណែកឯប្រាំមួយនាក់ទៀតមានអារម្មណ៍ស្ទាក់ស្ទើរមិនច្បាស់លាស់[54]។ អ្នកឆ្លើយតបចំនួន ១៩នាក់ ដែល *មិន*ចង់ឲ្យសំណុំរឿងទាំងនេះបន្តទៅមុខទៀតឡើយ ដោយគិតថាកិច្ចដំណើរការនីតិវិធីមានរយៈពេលយូរពេក និង/ឬ លើកឡើងពីកង្វល់នានាអំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាល និងការភ័យខ្លាចពីចលាចលក្នុងសហគមន៍របស់ពួកគេ ជាពិសេស អ្នកដែលបានរស់នៅក្នុងទីតាំងដ៏រឹងមាំរបស់ខ្មែរក្រហម ឬជាអតីតកម្មាភិបាលខ្លួនឯងផ្ទាល់តែម្តង[55]។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សារបស់ OSJI បានកត់សម្គាល់ថា ការភ័យខ្លាចរបស់អ្នកឆ្លើយតបអំពីចលាចលនោះជាទូទៅផ្អែកលើការយល់ច្រឡំពីរយ៉ាង៖ (១) យល់ច្រឡំថាសំណុំរឿង០០៣ និង ០០៤ នឹងផ្តោតលើមេដឹកនាំថ្នាក់ទាប និង (២) យល់ច្រឡំថានឹងមានសំណុំរឿងហួសពីសំណុំរឿង ០០៣ និង ០០៤ ទៀត ដែលបន្តដល់ថ្នាក់ក្រោមនៃឋានុក្រមកម្ពុជាប្រជាធិបតេយ្យ[56]។

33. មជ្ឈមណ្ឌល WSD HANDA សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (WSD HANDA Center for Human Rights and International Justice) នៅសកលវិទ្យាល័យ Standford និងមជ្ឈមណ្ឌលបស្ចឹមបូព៌ា (East-West Center) បានធ្វើការសិក្សាស្រាវជ្រាវមួយក្នុងឆ្នាំ២០១៧ ជាមួយនឹងក្រុមផ្តោតចំនួនប្រាំបី ដែលមាននិស្សិតចំនួន ៨៣នាក់ មកពីសាកលវិទ្យាល័យក្នុងរាជធានីភ្នំពេញ[57]។ ទោះបីជាសំណាកមានចំនួនតិច ដែលផ្អៀងទៅរកអ្នកដែលមានចំណាប់អារម្មណ៍ពីមុន និងមានតែយុវវ័យដែលអាចបន្តការសិក្សាកម្រិតខ្ពស់ក៏ដោយ[58] ក៏អ្នកចូលរួមជានិស្សិតបានកំណត់អត្តសញ្ញាណកេរ្តិ៍តំណែលសំខាន់របស់ អ.វ.ត.ក តាមលំដាប់លំដោយដូចជា៖ (១) ការបង្រៀន/ការទូន្មានជំនាន់ក្រោយអំពីអ្វីដែលបានកើតឡើង/ការសិក្សាអំពីការពិត (២) ផ្តល់យុត្តិធម៌ និងការផ្សះផ្សាសម្រាប់ជនរងគ្រោះ/ប្រជាជនកម្ពុជា (៣) ព្យាបាល/ដោះស្រាយការឈឺចាប់ពីអតីតកាល (៤) ការទប់ស្កាត់ការកើតមានឡើងវិញនៃឧក្រិដ្ឋកម្ម និង (៥) ការកាត់ទោស និង/ឬ ការដាក់ទោសមេដឹកនាំខ្មែរក្រហម[59]។ ស្រដៀងគ្នានេះដែរ ការសិក្សាស្រាវជ្រាវមួយក្នុងឆ្នាំ២០១១ ដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស (Human Rights

---

[54] ការសិក្សាដោយ OSJI ទំព័រ៨២។

[55] ការសិក្សាដោយ OSJI ទំព័រ ៨២-៨៣។

[56] ការសិក្សាដោយ OSJI ទំព័រ ៨៣។

[57] McCaffrie, C., *និងគូកន*, "ដូច្នេះយើងអាចដឹងអ្វីដែលបានកើតឡើង៖ សក្តានុពលអប់រំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" Stanford: មជ្ឈមណ្ឌល WSD HANDA សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ មជ្ឈបណ្ឌលបស្ចឹមបូព៌ា មករា ២០១៨ ("ការសិក្សាដោយ Handa") ទំព័រ៦។

[58] ការសិក្សាដោយ Handa ទំព័រ ៧។

[59] ការសិក្សាដោយ Handa ទំព័រ ១៩។

Center) នៅសាលាច្បាប់ Berkeley ដែលបានជ្រើសរើសអ្នកចូលរួមចំនួន ១០០០នាក់ ពីភូមិដែលជ្រើសរើសព្រាវចំនួន ២៥០ភូមិ ដើម្បីវាយតម្លៃពីការយល់ដឹង ទស្សនៈ និងឥរិយាបទរបស់ប្រជាជនកម្ពុជាចំពោះការកសាងសង្គមឡើងវិញ និង អ.វ.ត.ក[60]។ អ្នកចូលរួមភាគច្រើន (៨៣ ភាគរយ) ឯកភាពថា អ.វ.ត.ក គួរតែចូលរួមក្នុងការឆ្លើយតបទៅនឹងអ្វីដែលបានកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, អ្នកចូលរួម ៨៣ភាគរយ ឯកភាពថា ចាំបាច់ត្រូវរកការពិតអំពីអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៨៣ ភាគរយជឿជាក់ថាប្រជាជនមិនអាចមានអារម្មណ៍ធូរស្បើយបានទេ ប្រសិនបើពួកគេមិនបានដឹងពីអ្វីដែលបានកើតឡើងចំពោះមនុស្សជាទីស្រឡាញ់របស់ពួកគេ[61]។ គោលបំណងទាំងអស់នេះនឹងត្រូវបំពេញបន្ថែមទៀតតាមរយៈដំណើរទៅមុខនៃសំណុំរឿង ០០៣, ០០៤, និង ០០៤/២ (ប្រសិនបើភស្តុតាងតម្រូវឲ្យធ្វើដូច្នេះ) និងជាគោលដៅពិតប្រាកដដែលនាំឲ្យមានការបង្កើតតុលាការនេះឡើង។

34. ផ្អែកលើលទ្ធផលពីការសិក្សាស្រាវជ្រាវទាំងនេះ និងការពិចារណាថា សំណុំរឿង០០៣, ០០៤ និង ០០៤/២ ទាំងអស់ រួមបញ្ចូលបញ្ហា និងទីតាំងឧក្រិដ្ឋកម្មដែលមិនមែនជាកម្មវត្ថុនៃសំណុំរឿង០០១ ឬ០០២ មានប្រជាជនកម្ពុជា ជនរងគ្រោះ និងសមាជិកគ្រួសាររបស់ជនរងគ្រោះជាច្រើនមានចំណាប់អារម្មណ៍ខ្លាំងក្នុងការដឹងឮការពិតអំពីអ្វីដែលបានកើតឡើងនៅតាមទីតាំងទាំងអស់នេះ និងអំពីអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៣៤ នាក់ ដែលបានដាក់ពាក្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ និងត្រូវបានទទួលយកដោយ សចសអ[62] ពិតជាមិនជឿថាយុត្តិធម៌ត្រូវបានផ្តល់ជូនពេញលេញដោយសំណុំរឿង០០១ និង ០០២ នេះទេ ឬថា ពួកគេពុំគួរណាដាក់ពាក្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបន្ថែមនេះទេ។ ជាងនេះទៀត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែល ស.ច.ស.អ បានប្រកាសថាមិនអាចទទួលយកបាន ក៏មានចំណាប់អារម្មណ៍ខ្លាំងក្នុងការ

---

[60] Pham, PN *និងគូកន*., "បន្ទាប់ពីការជំនុំជម្រះលើកទីមួយ៖ ការស្ទង់មតិប្រជាជនស្តីពីការយល់ដឹង និងទស្សនៈលើយុត្តិធម៌ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" មជ្ឈមណ្ឌលសិទ្ធិមនុស្ស សាកលវិទ្យាល័យ California, Berkeley, មិថុនា ២០១១ ("ការសិក្សាដោយ Berkeley") ទំព័រ១៦។ *សម្គាល់*ថា ទោះបីជាការសិក្សានេះត្រូវបានបោះពុម្ពផ្សាយក្នុងខែមិថុនា ឆ្នាំ២០១១ ព័ត៌មានត្រូវបានប្រមូលក្នុង២០ថ្ងៃដំបូង នៃខែធ្នូ ឆ្នាំ២០១០។

[61] ការសិក្សាដោយ Berkeley Study ទំព័រ២៦, ៣១។ *សម្គាល់*ថា តួលេខទាំងបីនេះឆ្លុះបញ្ចាំងលទ្ធផលការសិក្សាឆ្នាំ ២០១០/២០១១ (ជាជាងលទ្ធផលជាមូលដ្ឋានឆ្នាំ ២០០៨)។

[62] ឯកសារ **D362.1** ឧសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ឧបសម្ព័ន្ធភ្ជាប់ទៅនឹងឯកសារ **D362** ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

ចូលរួមក្នុងសំណុំរឿង០០៤/២ ដែរ ប្រសិនបើវាដំណើរការទៅមុខ ដូច្នេះហើយបានជាពួកគេប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបានរបស់ ស.ច.ស.អ ដើម្បីបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនោះ[63]។

35. ផ្អែកលើហេតុផលនានាដែលបានរៀបរាប់ខាងលើ អំណះអំណាងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ដែលថា អោ អាន មិនគួរបញ្ជូនទៅជំនុំជម្រះ ដោយសារតែ "យុត្តិធម៌សម្រាប់" ជនរងគ្រោះអាចទទួលយកបានហើយ និងត្រូវគ្របដណ្តប់ដោយការជំនុំជម្រះសំណុំរឿង ០០១ និង ០០២ នោះ មិនគួរឱ្យជឿជាក់បានឡើយ[64]។

## IV. សំណូមពរ

36. ស.ព.អ សូមស្នើឱ្យ អ.ប.ជ ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ហើយតម្កល់ការសន្និដ្ឋានរបស់ ស.ច.ស.អ ថា អោ អាន គឺជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ និងបញ្ជូនសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ | លោក Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[63] *សូមមើល* ឯកសារ **D362/5** បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ និងឧបសម្ពន្ធដែលភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍នេះ។

[64] ឯកសារ **D360/8/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ ៩៦។